# ធម្មទេសនារបស់លោកអភិបាលអូលីវីយេ
# អភិបូជាបុណ្យចម្លងនៅផ្សារតូច
# ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៨
## *តើខ្ញុំជានរណា?*

អត្ថបទទី១៖ អស ១២
អត្ថបទទី២៖ រម ៦,៣-១១
ដំណឹងល្អ៖ មក ១៦,១-៧

បងប្អូនជាទីស្រឡាញ់!

ពិតមែន យប់នេះយើងទាំងអស់គ្នាអបអរសាទរព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ អាលេលូយ៉ា! អាលេលូយ៉ា!។ យប់នេះ យើងបានច្រៀងកោតសរសើរព្រះជាម្ចាស់ម្តងទៀត ជាមួយក្រុមទេវទូតទាំងអស់ដូចនៅក្នុងយប់បុណ្យណូអែល **"សូមលើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់នៅស្ថានដ៏ខ្ពង់ខ្ពស់បំផុត ហើយសូមឲ្យមនុស្សលោកដ៏ជាទីស្រឡាញ់របស់ព្រះអង្គបានសេចក្តីសុខសាន្ត"**។ ព្រះយេស៊ូគ្រីស្ត ដែលចាប់កំណើតជាមនុស្សនៅក្នុងក្រោលគោ នៅពេលនោះយើងបានកោតសរសើរព្រះយេស៊ូដែលជាកូនង៉ែតមួយយ៉ាងតូចជាមួយព្រះនាងម៉ារីជាមួយលោកយ៉ូសែប ដោយដាក់ឈ្មោះថា **"ព្រះអម្ចាស់នៃសន្តិភាព"**។ ព្រះយេស៊ូ ដែលយប់នេះមានព្រះជន្មរស់ឡើងវិញ ដែលណែនាំឲ្យយើងយល់អំពីអត្ថន័យនៃជីវិតរបស់ព្រះយេស៊ូ។ ពីភូមិបេថ្លេហិម ទៅដល់ភូមិណាសារ៉ែតទៅដល់ទីក្រុងយេរូសាឡឹម ដោយឆ្លងកាត់ស្រុកកាលីឡេ ស្រុកយូដេ និងស្រុកសាម៉ារី ព្រះយេស៊ូបានបង្ហាញអំពីព្រះយេស៊ូជាព្រះជាម្ចាស់ ជាព្រះបុត្រាយ៉ាងពិតប្រាកដមែន។

សូមបងប្អូននឹកឃើញនៅពេលព្រះយេស៊ូប្រសូត ប្រសូតតាមរបៀបសាមញ្ញធម្មតាដ៏កំពូល។ ព្រះជាម្ចាស់ដែលកើតជាមនុស្ស នៅកន្លែងដែលក្រីក្របំផុត ប៉ុន្តែយប់ហ្នឹងយើងមានទេវទូតដែលរំឭកយើង **"កូនង៉ែតនេះជាព្រះជាម្ចាស់ហើយ"**។ សូមបងប្អូននឹកឃើញនៅពេលដែលព្រះយេស៊ូបានទទួលពិធីជ្រមុជទឹក នៅក្នុងទន្លេយូដាន់ដូចប្រជាជនឯទៀតៗ ប៉ុន្តែនៅពេលនោះ មានសត្វព្រាបនិងមានព្រះសូរសៀងដែលប្រាប់ដល់យើងថា **"នេះជាព្រះបុត្រាដ៏ជាទីស្រឡាញ់របស់ខ្ញុំ"**។ ព្រះយេស៊ូ ដែលមានជីវិតសាមញ្ញធម្មតានៅក្នុងភូមិណាសារ៉ែត ជាជាងឈើដែលនៅស្ងៀមស្ងាត់អស់រយៈ៣០ឆ្នាំ ជាព្រះយេស៊ូហ្នឹងដែលបានធ្វើដំណើរពីភូមិមួយទៅភូមិមួយ ដើម្បីឲ្យអ្នកជំងឺជាសះស្បើយ ដើម្បីឲ្យអ្នកក្រីក្រមានសេចក្តីសង្ឃឹម ដើម្បីឲ្យអ្នកជាប់បាបទទួលការលើកលែងទោស។ ព្រះយេស៊ូ ដែលបានណែនាំមហាជនពោរពេញដោយអំណរសប្បាយនិងសេចក្តីសង្ឃឹម ព្រះយេស៊ូដែលបានរំខាន

មហាបូជាចារ្យ និងគណៈផារីស៊ី។ ព្រះយេស៊ូ ដែលបានណែនាំឲ្យគេអន់ចិត្តជាមួយព្រះយេស៊ូរហូតដល់គេចាប់ព្រះយេស៊ូ សម្លាប់ព្រះយេស៊ូដូចជាឃាតករដ៏កំពូលបំផុត ដោយសារព្រះយេស៊ូបានប្រកាសនៅមុនគេបង្អស់ "**ព្រះយេស៊ូជាព្រះជាម្ចាស់**"។ ឲ្យយើងនឹកឃើញដែរនៅពេលព្រះយេស៊ូនិងក្រុមគ្រីស្តទូត នៅពេលព្រះយេស៊ូកំពុងធ្វើដំណើរជាមួយក្រុមគ្រីស្តទូតយ៉ាងស្ងៀមស្ងាត់ នៅពេលនោះបន្តិចម្តងៗព្រះយេស៊ូបានបង្ហាញខ្លួនឲ្យក្រុមគ្រីស្តទូតទទួលស្គាល់ **ព្រះយេស៊ូជានរណា?** នៅនោះពេលព្រះយេស៊ូបានសួរសម្រាប់គេ "**តើខ្ញុំជានរណា?**" គេថាព្យាការីយ៉ូហានបាទីស្ទ អេសាយ អេលី...។ល។ សម្រាប់ក្រុមគ្រីស្តទូតព្រះយេស៊ូសួរម្តងទៀត "**ខ្ញុំជានរណា?**" ហើយនៅពេលនោះមានតែលោកសិលាដែលហ៊ានឆ្លើយថា "**ព្រះអង្គជាព្រះបុត្រ ព្រះអង្គជាព្រះគ្រីស្តពិតមែន**"។ ព្រះយេស៊ូដែលហ៊ានបង្ហាញខ្លួននៅលើភ្នំ ដើម្បីឲ្យលោកសិលា លោកយ៉ាកុប និងលោកយ៉ូហាន ឃើញសិរីរុងរឿងរបស់ព្រះអង្គ។ ព្រះយេស៊ូ ដែលបានឲ្យជីវិតដោយផ្ទាល់ខ្លួនដល់ស្ត្រីសាសន៍សាម៉ារីដែលស្រេកទឹក និងយប់ដែលព្រះយេស៊ូជប់លៀងចុងក្រោយពីរថ្ងៃមុន ព្រះយេស៊ូបានយកនំប៉័ង បានយកស្រា និងមានព្រះបន្ទូលថា "**នេះជាព្រះកាយរបស់ខ្ញុំ នេះជាព្រះលោហិតរបស់ខ្ញុំ**" នៅពេលនោះគឺព្រះយេស៊ូផ្ទាល់ ដែលប្រទានខ្លួនផ្ទាល់ដល់ក្រុមគ្រីស្តទូត ព្រះយេស៊ូដែលបូជាជីវិតយ៉ាងពិតប្រាកដមែន រហូតដល់បូជាជីវិតឲ្យយើងមើលឃើញពីម្សិលមិញនៅលើឈើឆ្កាង។ យប់នេះ យើងស្តាប់ទេវទូតម្តងទៀតដូចនៅថ្ងៃបុណ្យព្រះយេស៊ូប្រសូត និងយប់នេះទេវទូត និយាយទៅដល់ស្ត្រីៗដែលមកផ្នូររបស់ព្រះយេស៊ូថា "**ព្រះអង្គយាងទៅស្រុកកាលីឡេមុនអ្នករាល់គ្នា នៅទីនោះអ្នករាល់គ្នានឹងឃើញព្រះអង្គដូចទ្រង់មានព្រះបន្ទូលស្រាប់**"។ ព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ អាលេលូយ៉ា! នេះជាសេចក្តីប្រកាសរបស់ទេវទូតយប់នេះសម្រាប់ស្ត្រីៗ និងសម្រាប់យើងទាំងអស់ ព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ អាលេលូយ៉ា!។ ពិតមែនព្រះសពរបស់ព្រះអង្គ ដែលយើងបានបញ្ចុះក្នុងផ្នូរពីរថ្ងៃមុននៅពេលព្រឹកឡើងពេលស្ត្រីទៅដល់ផ្នូរអស់សពហើយ សពរបស់ព្រះយេស៊ូបាត់ហើយ។

បងប្អូនជាទីស្រឡាញ់!

យប់នេះ នៅទល់មុខរបស់យើងផ្ទាល់ យើងមិនសម្លឹងមើលកូនង៉ែតដែលបានប្រសូតនៅភូមិបេថ្លេហឹម ប៉ុន្តែយើងកំពុងឈរនៅក្បែរផ្នូរដែលគេបានដាក់សពរបស់ព្រះ

យេស៊ូបីថ្ងៃមុន និងនៅពេលនោះសពព្រះយេស៊ូបានបាត់ហើយ ដោយសារព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ។ អម្បាញ់មិញយើងបានស្តាប់អត្ថបទគម្ពីរយ៉ាងច្រើន ដើម្បីរំឭកដល់ប្រវត្តិសាស្ត្រនៃការសង្គ្រោះយើងខ្ញុំ ព្រះជាម្ចាស់បានបង្កើតយើងជាបុរសជាស្ត្រី ឲ្យមានលក្ខណៈដូចព្រះជាម្ចាស់។ ព្រះជាម្ចាស់ដែលមានព្រះហឫទ័យដ៏ស្មោះត្រង់បំផុត ដែលរំដោះប្រជារាស្ត្រអ៊ីស្រាអែល ពីកណ្តាប់ដៃជនជាតិអេស៊ីប។ ព្រះជាម្ចាស់ ដែលស្រឡាញ់មនុស្សលោកខ្លាំងណាស់ ហេតុនេះហើយបានចាត់ព្រះបុត្រាដ៏ជាទីស្រឡាញ់របស់ព្រះអង្គដើម្បីយាងមកក្នុងពិភពលោកនេះ ចាប់កំណើតជាមនុស្សដើម្បីមនុស្សលោកទទួលជីវិតនិងជីវិតអស់កល្បជានិច្ច។ យប់នេះ យើងមើលឃើញព្រះបន្ទូលសន្យារបស់ព្រះជាម្ចាស់ទៅជារូបរាងដ៏ពិតប្រាកដមែន។ នៅយប់នេះសម្ពន្ធមេត្រីថ្មី បានចងអស់កល្បជានិច្ច។ ពីម្សិលមិញយើងឃើញហើយនៅលើឈើឆ្កាងមានឈាម មានទឹក ហូរចេញពីទ្រូងរបស់ព្រះយេស៊ូ។ យប់នេះ នៅក្នុងព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ យើងមើលឃើញជាក់ស្តែងព្រះជាម្ចាស់ចងជាមួយយើងជាមួយពិភពលោកទាំងមូល សម្ពន្ធមេត្រីថ្មីស្ថិតស្ថេរដែលណែនាំឲ្យយើងទាំងអស់ អាចចូលរួមនៅក្នុងជីវិតអស់កល្បជានិច្ច។ យប់នេះជាយប់ដ៏ពិសេសបំផុត ដោយសារការប្រយុទ្ធរវាងអំពើអាក្រក់និងអំពើល្អបានបញ្ឈប់ហើយ។ យប់នេះអំពើល្អបានឈ្នះអស់កល្បជានិច្ចនៅលើគ្រប់អំពើអាក្រក់។ យប់នេះ គឺពន្លឺដែលបានឈ្នះអស់កល្បជានិច្ចនៅលើគ្រប់ភាពងងឹត។ យប់នេះ ពិតមែនសេចក្តីស្លាប់បានបរាជ័យអស់ហើយ ព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ ព្រះយេស៊ូបានណែនាំឲ្យជីវិតពួកយើងជាជីវិតដែលចង្អៀតចង្អល់ ជីវិតរបស់យើងមានព្រំដែនច្រើន នៅក្នុងដួងចិត្តរបស់យើងដោយសារចិត្តច្រណែន ចិត្តលោភលន់ ដោយសារអំពើបាប ដោយសារគំនិតប្លែកៗ ដែលណែនាំឲ្យមនុស្សមួយចំនួនអស់សង្ឃឹមហើយដោយសារយើង។ ជីវិតរបស់យើង ជាជីវិតចង្អៀតចង្អល់ដែលមានព្រំដែនយ៉ាងច្រើន ដោយសារអំពើបាបរបស់យើងដែលណែនាំឲ្យយើងបន្តិចម្តងៗយើងស្លាប់។ ប៉ុន្តែយប់នេះ ព្រះយេស៊ូបានបើកផ្លូវថ្មី ផ្លូវដែលគ្មានព្រំដែន ផ្លូវដែលមានជីវិតអស់កល្បជានិច្ច ដោយណែនាំឲ្យមនុស្សទាំងអស់ចូលទៅក្នុងព្រះហឫទ័យគ្មានព្រំដែនរបស់ព្រះជាម្ចាស់។

ថ្ងៃសៅរ៍ពិសិដ្ឋ ជាថ្ងៃដែលណែនាំឲ្យព្រះសហគន៍យើងទាំងអស់ ចូលទៅក្នុងភាពសម្ងាត់ និងនៅក្នុងថ្ងៃនោះព្រះយេស៊ូបានទៅឋានក្រោម ដើម្បីចូលនៅក្នុងភាពងងឹតដែល

ជ្រៅបំផុតរបស់មនុស្សលោក ដើម្បីចូលនៅក្នុងទុក្ខលំបាកដែលពិបាកបំផុតនៃមនុស្សលោក ដើម្បីចូលនៅក្នុងជីវិតរបស់ខ្ញុំផ្ទាល់ នៅពេលជីវិតរបស់ខ្ញុំអស់សង្ឃឹម នៅពេលជីវិតរបស់ខ្ញុំមើលមិនឃើញពន្លឺដើម្បីទៅមុខ។ នៅថ្ងៃសៅរ៍នេះ ព្រះយេស៊ូបានចូលនៅក្នុងដួងចិត្តរបស់យើងយ៉ាងជ្រៅ ដើម្បីណែនាំឲ្យយើងទាំងអស់ចេញពីភាពងងឹត ចេញពីអំពើអាក្រក់ ចេញពីអ្វីដែលណែនាំឲ្យយើងអស់សង្ឃឹម ដើម្បីចូលទៅក្នុងទឹកដីដែលសន្យា ប៉ុន្តែមិនមែនទឹកដីរបស់ប្រជារាស្ត្រអ៊ីស្រាអែល ដែលលោកម៉ូសេបានណែនាំឲ្យគេទៅ៤០ឆ្នាំតាមវាលរហោស្ថាន។ ប៉ុន្តែយប់នេះ ព្រះយេស៊ូបានណែនាំឲ្យយើងចេញពីអំពើបាប ពីជីវិតដែលអស់សង្ឃឹមដើម្បីចូលទៅក្នុងទឹកដីថ្មី គឺទឹកដីដែលណែនាំឲ្យយើងមានជីវិតអស់កល្បជានិច្ចគឺ **ព្រះរាជ្យរបស់ព្រះជាម្ចាស់**។ នៅពេលព្រះយេស៊ូចេញពីភូមិណាសារ៉ែត ទៅស្រុកកាលីឡេព្រះយេស៊ូមានព្រះបន្ទូលថា "**ព្រះរាជ្យរបស់ព្រះជាម្ចាស់ជិតមកដល់ហើយ! ចូរកែប្រែចិត្តគំនិត ស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ទៅ!**"។ នៅក្នុងបីឆ្នាំ យើងបានស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ដូចក្រុមគ្រីស្តទូត នៅក្នុងជីវិតរបស់យើង យើងយកចិត្តទុកដាក់ស្តាប់ព្រះបន្ទូលរបស់ព្រះគ្រីស្ត ដើម្បីយប់នេះយើងមើលឃើញព្រះរាជ្យរបស់ព្រះជាម្ចាស់។

បងប្អូនជាទីស្រឡាញ់!

ដោយអគ្គសញ្ញាជ្រមុជទឹករបស់យើង យប់នេះយើងមានអំណរសប្បាយដោយសារយើងមាន៧នាក់ ដែលទទួលជីវិតថ្មីនៅក្នុងព្រះសហគមន៍សន្តយ៉ូសែបយើង។ នៅក្នុងភូមិភាគភ្នំពេញយើងមាន៨០នាក់ ដែលទទួលជីវិតថ្មីនៅក្នុងយប់នេះ។ យប់នេះដែលយើងទទួលជីវិតថ្មីរួមជាមួយព្រះយេស៊ូ មានន័យថា រួមស្លាប់ រួមរស់ ជាមួយព្រះយេស៊ូ យប់នេះដូចសន្តប៉ូលយើងហ៊ាននិយាយថា "**មិនមែនខ្ញុំដែលនៅរស់តទៅទៀត គឺព្រះគ្រីស្តដែលរស់នៅក្នុងជីវិតរបស់ខ្ញុំហើយ**"។

អាលេលូយ៉ា! ព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ នៅក្នុងចំណោមមនុស្សស្លាប់ទាំងឡាយ ព្រះយេស៊ូបានឈរឡើង។ នេះមិនមែនការអស្ចារសម្រាប់មនុស្សម្នាក់ ដូចព្រះយេស៊ូបានប្រោសលោកឡាសាឲ្យមានជីវិតសារជាថ្មី ព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញមិនមែនការអស្ចារ្យសម្រាប់ព្រះយេស៊ូតែម្នាក់គត់ ប៉ុន្តែគឺការអស្ចារ្យសម្រាប់យើងទាំងអស់ដោយសារយប់នេះយើងដឹងថា ព្រះជាម្ចាស់ដែលស្រឡាញ់មនុស្សលោកយ៉ាងខ្លាំងណាស់

ដែលស្រឡាញ់យើងរៀងៗខ្លួន ណែនាំឲ្យយើងចូលនៅក្នុងជីវិតអស់កល្បជានិច្ចរួមជាមួយព្រះយេស៊ូនៅក្នុងយប់នេះ។ យើងទទួលព្រះអំណោយទានរបស់ព្រះជាម្ចាស់យប់នេះ ជាព្រះអំណោយទានដ៏អស្ចារ្យបំផុត ដោយសារជំនឿរបស់យើង ដោយសារអគ្គសញ្ញាជ្រមុជទឹករបស់យើង យើងចូលនៅក្នុងពិភពថ្មីមួយ ពិភពមួយដែលគ្មានព្រំដែន គឺពិភពរបស់ព្រះជាម្ចាស់។ ជំនឿរបស់យើង ណែនាំឲ្យយើងចូលនៅក្នុងសេចក្តីស្រឡាញ់ដ៏គ្មានព្រំដែន សេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់។ យើងជាសាវ័ករបស់ព្រះគ្រីស្ត ដោយសារអគ្គសញ្ញាជ្រមុជទឹករបស់យើង យើងជាមិត្តសម្លាញ់យ៉ាងជិតស្និទ្ធរបស់ព្រះយេស៊ូ យើងបានរួមស្លាប់រួមរស់ជាមួយព្រះយេស៊ូ យប់នេះព្រំដែននៃជីវិតរបស់យើង ព្រំដែននៃសេចក្តីស្លាប់របស់យើង ផ្ទុះអស់ហើយ អស់ព្រំដែនហើយ។ យប់នេះ ព្រំដែននៃពិភពលោករបស់យើងដែលប៉ុន្មានដងប៉ុន្មានសារយើងឃើញពិភពលោករបស់យើង ចង្អៀតចង្អល់ដោយសារការស្អប់គ្នា ដោយសារមិនយល់ចិត្តគ្នា ដោយសារមិនអើពើគ្នាទៅវិញទៅមក។ យប់នេះ ជីវិតរបស់ព្រះជាម្ចាស់ផុះឡើង ផុសឡើង នៅលើផែនដីទាំងមូលដូចយើងបាញ់កាំជ្រួចដែលទៅឆ្ងាយៗនៅលើផ្ទៃមេឃ យប់នេះជីវិតអស់កល្បជានិច្ចរបស់ព្រះយេស៊ូទៅគ្រប់ទីកន្លែងនៅក្នុងពិភពលោកយើង។

ចាប់ពីពេលនេះតទៅ បងប្អូនជាទីស្រឡាញ់ជឿពិតមែនលែងមានព្រំដែន លែងមានសង្គ្រាមរវាងមនុស្សនិងមនុស្ស រវាងសាសនានិងសាសនា។ ប៉ុន្តែមានតែប្រជាជនដែលយល់ចិត្តគ្នានិងដែលចូលរួមនៅក្នុងសុបិន្តតែមួយ **"ធ្វើយ៉ាងដូចម្តេចឲ្យមនុស្សយើងសម្រុះសម្រួលគ្នា ដើម្បីរស់នៅក្នុងសុខដុមរមនានិងនៅក្នុងសេចក្តីសុខសាន្ត?"** យប់នេះលែងមានរបង ដើម្បីបាក់បែកគ្នារវាងអ្នកក្រីក្រនិងអ្នកមាន។ ប៉ុន្តែមានតែបងប្អូនបង្កើតដែលសុខចិត្តជួយគ្នាទៅវិញទៅមក ដើម្បីណែនាំឲ្យយើងរៀងៗខ្លួនរីកចម្រើនតាមសមត្ថភាពរបស់យើង ប៉ុន្តែអស់ពីសមត្ថភាពរបស់យើង។ យប់នេះលែងមានមនុស្សដែលមើលងាយគ្នាទៅវិញទៅមក មើលងាយអ្នកតូចតាចដែលមិនមែនដូចយើងនិងគ្នាឯងដោយសារយប់នេះ មានតែចិត្តគំនិតដែលចេះគោរពគ្នាទៅវិញទៅមក ជាពិសេសគោរពភាពប្លែកនៃគ្នាទៅវិញទៅមក។ យប់នេះ លែងមានក្រុមគ្រួសារដែលបាក់បែកគ្នា ប៉ុន្តែមានតែប្តីប្រពន្ធ មានតែឪពុកម្តាយ មានតែកូនៗ ដែលលើកលែងទោសឲ្យគ្នាទៅវិញទៅមក ដើម្បីបន្តធ្វើដំណើរដូចបានចាប់ផ្តើមពីដើម ដើម្បីឲ្យក្រុមគ្រួសារទៅជាគ្រួសារដ៏សុខសាន្ត

ទោះបីយើងដឹងថាត្រូវតែមានទុក្ខលំបាក និងត្រូវតែមានបញ្ហាក៏ដោយដោយសារនេះជាជីវិត។ យប់នេះ លែងមានការបាក់បែកគ្នានៅក្នុងព្រះសហគមន៍ និងនៅក្នុងសង្គម ប៉ុន្តែមានតែដួងចិត្តដែលមានអំណរសប្បាយដ៏ពេញលក្ខណៈ ដោយសារយើងយកចិត្តទុកដាក់ដើម្បីធ្វើការជាមួយគ្នា ដើម្បីគិតពីផលប្រយោជន៍រួម ដើម្បីគិតអំពីអំណរសប្បាយ និងសុភមង្គល មិនមែនសុភមង្គលរបស់ខ្ញុំ ប៉ុន្តែជាសុភមង្គលរបស់បងប្អូនឯទៀតៗ។ យប់នេះ យើងលែងមើលងាយពិភពលោករបស់យើង ធម្មជាតិរបស់យើង បរិស្ថានរបស់យើង ដោយសារយប់នេះយើងយកចិត្តទុកដាក់តាមការថែទាំធម្មជាតិ ស្រឡាញ់បរិស្ថានពិភពលោក ដែលព្រះជាម្ចាស់បានបង្កើត បានប្រទានឲ្យយើងថែរក្សា។ យប់នេះ លែងមានមនុស្សដែលមិនអើពើអំពីអ្នកដទៃ ដែលទុកចោលមនុស្សតូចតាចនៅលើផ្លូវ។ យប់នេះមានតែមនុស្សដែលអើពើដល់អ្នកដទៃ អ្នកតូចអ្នកធំ ដោយសារយើងដឹងថាជីវិតមានតម្លៃណាស់ និងជីវិតមានតម្លៃថ្លៃថ្នូរស្មើៗគ្នា។ យប់នេះ លែងមានមនុស្សដែលសម្រេចចិត្តសម្លាប់កូននៅក្នុងផ្ទៃពោះម្ដាយ លែងមានមនុស្សដែលសម្លាប់ខ្លួន ដោយសារចាស់ពេក ដោយសារគិតថាលែងមានប្រយោជន៍នៅក្នុងសង្គម ឬដោយសារមានជំងឺខ្លាំងពេក ដោយសារយើងដឹងថាទាំងជីវិតទាំងសេចក្ដីស្លាប់ ជាអំណោយទានយ៉ាងពិសេសដែលយើងទទួលពីព្រះជាម្ចាស់ ជាអំណោយទានយ៉ាងពិសេសបំផុត ដែលព្រះជាម្ចាស់ប្រទានឲ្យយើង។ អម្បាញ់មិញខ្ញុំបានទទួលសារមួយពីគ្រូបង្រៀនម្នាក់ដែលខ្ញុំស្គាល់ គាត់បានស្ដាប់ខ្ញុំទេសនាពីរទៅបីដងគាត់ថាខ្ញុំសប្បាយចិត្តពេលខ្ញុំស្ដាប់លោកអភិបាល គាត់សួរថា **ធ្វើដូចម្ដេច ដើម្បីឲ្យពិភពលោករបស់យើងមានសេចក្ដីសុខ?** និងខ្ញុំឆ្លើយទៅគាត់នូវអ្វីដែលខ្ញុំនិយាយអម្បាញ់មិញ។ វាមិនមែនជាសុបិន្តរបស់ព្រះយេស៊ូទេ មិនមែនសុបិន្តរបស់លោកអភិបាល ឬលោកឪពុកដែលមានទស្សនៈអស្ចារ្យ ប៉ុន្តែជាអ្វីដែលយើងឃើញជាក់ស្ដែងយប់នេះ យើងទាំងអស់យើងបានចូលរួមនៅក្នុងនេះ ប្រសិនបើយើងជឿថាខ្ញុំផ្ទាល់ខ្លួនខ្ញុំមានសមត្ថភាព ដើម្បីឲ្យជីវិតខ្ញុំទៅជាជីវិតដែលពោរពេញដោយអំណរសប្បាយ ដោយសារខ្ញុំយកចិត្តទុកដាក់លើអ្នកដទៃ បន្តិចម្ដងៗពិភពរបស់យើង សង្គមរបស់យើង ទៅជាសង្គមថ្មីពិតៗ គឺស៊ីសងលើយើងម្នាក់ៗ។ អ្នកដែលទទួលអគ្គសញ្ញាជ្រមុជទឹកយប់នេះ ប្រសិនបើគេសម្រេចចិត្ត "ខ្ញុំមានជីវិតថ្មីពីព្រះយេស៊ូ ខ្ញុំធ្វើយ៉ាងម៉េចឲ្យបងប្អូនខ្ញុំ គ្រួសារខ្ញុំ អ្នកជិតខាងខ្ញុំ មានសេចក្ដីសុខ កុំឲ្យឈ្លោះគ្នា កុំឲ្យស្អប់គ្នា កុំឲ្យមើលងាយគ្នា កុំឲ្យនិយាយដើមគ្នា?" អ្វីៗទាំងអស់អាចកើតឡើងបាន។ ដូច្នេះខ្ញុំសង្ឃឹម នៅយប់នេះពេលយើងទៅផ្ទះវិញ ឲ្យយើងពោរពេញដោយ

កម្លាំងនៅក្នុងចិត្តហើយគិតថា "ខ្ញុំជាមនុស្សពិសេស ដោយសារព្រះយេស៊ូមាព្រះជន្មរស់ឡើងវិញសម្រាប់ខ្ញុំ។ ខ្ញុំជាមនុស្សពិសេស ហើយខ្ញុំមានសមត្ថភាពឲ្យសង្គមខ្ញុំ គ្រួសារខ្ញុំ ភូមិខ្ញុំ ទៅជាភូមិថ្មី គ្រួសារថ្មី និងសង្គមថ្មី។ យប់នេះ ដោយសារព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ អ្វីៗទាំងអស់អាចកើតឡើងបាន អ្វីៗទាំងអស់យើងអាចធ្វើបាន"។

បងប្អូនជាទីស្រាញ់!

២០០០ឆ្នាំមុន យើងនៅស្រុកកាលីឡេ ឥលូវនេះស្រុកកាលីឡេអស់ព្រំដែនហើយ ស្រុកកាលីឡេទៅជាពិភពលោកទាំងមូល មានន័យថានៅពេលនេះទេវទូតមិនណែនាំឲ្យយើងទៅស្រុកកាលីឡេ ប៉ុន្តែណែនាំឲ្យយើងទៅកន្លែងដែលយើងនៅ ដោយសារស្រុកកាលីឡេបានទៅដល់គ្រប់ទីកន្លែងក្នុងពិភពលោកទាំងមូល។ យប់នេះ ព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ និងណែនាំឲ្យយើងទាំងអស់កសាងពិភពថ្មីបាន លុះត្រាតែយើងមានដួងចិត្តទូលំទូលាយ ដែលចង់ស្វាគមន៍បងប្អូនឯទៀតៗ ឲ្យយើងទាំងអស់ចូលនៅក្នុងពិភពថ្មីដែលគ្មានព្រំដែន ពិភពដែលប្រៀបដូចជាព្រះហឫទ័យស្រឡាញ់របស់ព្រះជាម្ចាស់ សម្រាប់យើងដែលគ្មានព្រំដែន។

បងប្អូនជាទីស្រឡាញ់! យប់នេះឲ្យយើងក្រោកឈរឡើងដើម្បីត្រៀមខ្លួន ដោយសារព្រះជាម្ចាស់ បានជ្រើសរើសយើងឲ្យទៅជាបុត្រធីតារបស់ព្រះអង្គ ឲ្យទៅជាគ្រីស្តទូតដើម្បីទៅប្រកាសដំណឹងល្អ។ យប់នេះ ពិតមែនមិនមែនខ្ញុំដែលនៅរស់ ប៉ុន្តែជាព្រះយេស៊ូគ្រីស្តដែលរស់នៅក្នុងខ្ញុំ។ សូមឈរឡើង! ដោយសារភាពងងឹតបានបាត់អស់ហើយ យើងទាំងអស់គ្នាយើងជាកូននៃពន្លឺ ព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ។ អាលេលូយ៉ា! អាលេលូយ៉ា!។ អាម៉ែន៕